ខេត្តពោធិ៍សាត់

សក្តានុពលវិនិយោគ

ខែ មករា ឆ្នាំ ២០១០

USAID

ជំនួយពីពលរដ្ឋអាមេរិក




# ខេត្តពោធិ៍សាត់

## ជាផ្នែកមួយនៃការរីកចម្រើនរបស់យើង !








**បញ្ជាក់:**
ទស្សនៈរបស់អ្នកនិពន្ធដែលបង្ហាញនៅក្នុងឯកសារបោះពុម្ពផ្សាយនេះ មិនឆ្លុះបញ្ចាំងអំពីទស្សនៈរបស់ ទីភ្នាក់ងារសហរដ្ឋអាមេរិក ដើម្បីអភិវឌ្ឍន៍អន្តរជាតិ ឬ រដ្ឋាភិបាលអាមេរិកឡើយ ។




# របាយការណ៍វិនិយោគនៅខេត្តពោធិ៍សាត់


**សារស្វាគមន៍របស់ថ្នាក់ដឹកនាំខេត្ត ........................................ ២**

**ចំណុចខ្លាំងថ្នាក់ជាតិ ........................................ ៣**

បើកចំហចំពោះអាជីវកម្ម

កំលាំងពលកម្មតម្លៃទាប និងមានផលិតភាព

ទីតាំងជាយុទ្ធសាស្ត្រក្នុងតំបន់

**ហេតុផលប្រាំបីយ៉ាងក្នុងការធ្វើវិនិយោគក្នុងខេត្តពោធិ៍សាត់ ........................................ ៤**

១. ទីតាំងមូលដ្ឋានល្អសមស្របសម្រាប់ ពាណិជ្ជកម្មក្នុងស្រុក និងនាំចេញ

២. កម្លាំងពលកម្មវ័យក្មេង មានការអប់រំ និងមានតម្លៃទាប

៣. រដ្ឋអំណាចមូលដ្ឋានផ្តល់ការគាំទ្រ

៤. ការផ្គត់ផ្គង់អគ្គិសនីដែលអាចទុកចិត្តបាន

៥. មានអចលនវត្ថុតម្លៃខ្ពស់

៦. វិស័យសេវាកម្មហិរញ្ញវត្ថុ មានការរីកចម្រើន

៧. ទេសចរណ៍

៨. ធនធានធម្មជាតិដែលមិនទាន់ធ្វើអាជីវកម្ម

**វិស័យសំខាន់ៗរបស់ខេត្ត........................................ ៦**

**និកាសពាណិជ្ជកម្ម ........................................ ៦**

**ការអភិវឌ្ឍន៍ដែលកំពុងដំណើរការ ........................................ ៧**

**ត្រូវការស្វែងយល់បន្ថែមទៀតទេ? ........................................ ៨**


របាយការណ៍វិនិយោគនេះផលិតដោយ Emerging Markets Consulting សំរាប់ គម្រោងពង្រឹងសហគ្រាសខ្នាតតូចបំផុត ខ្នាតតូច និងខ្នាតមធ្យមកម្ពុជា ដែលអនុវត្តគំរោងដោយអង្គការ DAI ឧបត្ថម្ភថវិកាដោយ ទីភ្នាក់ងារសហរដ្ឋអាមេរិក ដើម្បីអភិវឌ្ឍន៍អន្តរជាតិ និងមានការចូលរួមសហការពីសាលាខេត្តពោធិ៍សាត់ និងគណៈកម្មាធិការវិនិយោគកម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។








# សារស្វាគមន៍របស់ថ្នាក់ដឹកនាំខេត្ត

ពោធិ៍សាត់ មានទីតាំងលើដងផ្លូវជាតិលេខ ៥ ខាងជើងទល់នឹងខេត្តបាត់ដំបង និងបឹងទន្លេសាប ខាងត្បូងទល់នឹងខេត្តកោះកុង និងកំពង់ស្ពឺ ខាងលិចទល់នឹងប្រទេសថៃឡង់ដ៍ និងខាងកើតទល់នឹងខេត្តកំពង់ឆ្នាំងដែលមានផ្ទៃដីទំហំ១២.៦៩២គីឡូម៉ែត្រការ៉េ ប្រជាជនសរុបចំនួន ៤២៦.៧៥៨ នាក់ ។

ការគ្រប់គ្រង និងការដឹកនាំដោយក្រុមប្រឹក្សាខេត្ត ដែលកើតចេញពីការបោះឆ្នោតមានអាណត្តិ ៥ ឆ្នាំ និងគណៈអភិបាលខេត្ត ដែលមានការតែងតាំងពីរាជរដ្ឋាភិបាលដែលមានអាណត្តិ ៤ ឆ្នាំ នេះជារចនាសម្ពន្ធ័មានចក្ខុវិស័យភ្លឺស្វាងល្អ ។

ទឹកដីខេត្តពោធិ៍សាត់ប្រកបទៅដោយធនធានធម្មជាតិសំបូរបែបទាំងលើ និងក្រោមដីដូចជាព្រៃឈើ ខ្សាច់សំណង់ ថ្មកែវ ត្រីទឹកសាប និងរ៉ែក្រោមដីមួយចំនួនទៀត... ។ល ។ និង ។ល ។

វិស័យសំខាន់ៗដែលទ្រទ្រង់សេដ្ឋកិច្ចរបស់ខេត្តមានជាអាទិ៍ គឺកសិកម្មផលិតស្រូវសំរាប់នាំចេញរួមផ្សំដំណាំផ្លែឈើជាច្រើនមុខ ពិសេសដំណាំក្រូចពោធិ៍សាត់ ជាប្រភពពូជក្រូចពោធិ៍សាត់ដែលមានរសជាតិឆ្ងាញ់ ហើយបានជ្រួតជ្រាបល្បីល្បាញទូទាំងប្រទេស រមណីយដ្ឋានទេសចរណ៍វប្បធម៌ដ៏ល្អស្រស់ត្រកាលដែលទាក់ទាញស្រូបយកភ្ញៀវទេសចរក្នុងមួយឆ្នាំប្រមាណ៣០ម៉ឺននាក់ ថាមពលវ៉ារីអគ្គិសនីកម្លាំង ១៧០ មេហ្គាវ៉ាត់ដ៏ធំលើសលុបពីសេចក្តីត្រូវការ ហើយនាំចេញទៅបណ្តាខេត្តដទៃទៀត ដែលអគ្គិសនីនេះបានបង្ហាញថាមពលរបស់ខ្លួននៅពេលដ៏ខ្លីខាងមុខនេះ និងវិស័យវប្បធម៌ក្បាច់បុរាណដែលគ្មានពីរក្នុងប្រទេស គឺថ្មកែវដែលជាផលិតផលមានចម្លាក់ល្អវិសេសវិសាលបានមកពីទឹកដៃប្រជាជនខេត្តពោធិ៍សាត់ដ៏យូរលង់ណាស់មកហើយ ។

វិស័យនានាទាំងអស់នេះគឺ ពិតជាធ្វើឱ្យទ្រព្យសម្បត្តិពាណិជ្ជកម្មកើនមានច្រើនដ៏លើសលុបដែលទាញយកសក្តានុពលដ៏អស្ចារ្យរបស់ខេត្តពោធិ៍សាត់ ដែលជាខេត្តមានប្រវត្តិអង់អាចក្លាហានកម្លាំងខ្លាំងក្លា ប្រាជ្ញាឈ្លាសវៃ សមដូចជាវិរៈបុរសរបស់យើងគឺ ឧកញ៉ាឃ្លាំងមឿង ។

យើងខ្ញុំសូមស្វាគមន៍ជានិច្ច សំរាប់ការអញ្ជើញមកដល់លើទឹកដីខេត្តពោធិ៍សាត់នូវវិនិយោគិនធុរៈជននានា ដែលមានបំណងធ្វើអាជីវកម្ម បង្វិលទុនលើគ្រប់វិស័យលើទឹកដី ដែលជាទឹកដីមាសពិតប្រាកដរបស់ខេត្តយើងខ្ញុំ ។

ពោធិ៍សាត់ ខែ មករា ឆ្នាំ ២០១០

ប្រធានក្រុមប្រឹក្សាខេត្តពោធិ៍សាត់

ឯកឧត្តម ឆាយ សារ៉េត

អភិបាលខេត្តពោធិ៍សាត់

ឯកឧត្តម ខូយ សុខា





## ចំណុចខ្លាំងថ្នាក់ជាតិ

អស់រយៈពេលជាងមួយទសវត្សរ៍កន្លងទៅនេះ ប្រទេសកម្ពុជាបានលេចឡើងជាប្រទេសក្នុងតំបន់ដែលមានតួនាទីរស់រវើក និង រឹងមាំជាមួយនឹងកេតនភណ្ឌជាមូលដ្ឋានជាច្រើនដែលចាំបាច់សម្រាប់ការអភិវឌ្ឍន៍ និងកំណើនអាជីវកម្មដោយជោគជ័យ ។

### បើកចំហចំពោះអាជីវកម្ម

- ពន្ធអាជីវកម្មទាប - ពន្ធ ២០% លើផលចំណេញអាជីវកម្ម (អាចអនុគ្រោះពន្ធដល់ ៥ ឆ្នាំ ចំពោះការខាតបង់) ។
- គ្មានការដាក់កំហិតលើម្ចាស់កម្មសិទ្ធិជាជនបរទេស (លើកលែងតែកម្មសិទ្ធិដីធ្លី) ។
- នាំមុខជាងបណ្តារប្រទេសមួយចំនួននៅក្នុងតំបន់ ចំពោះសេរីភាពសេដ្ឋកិច្ច[1] ។
- ប្រព្រឹត្តស្មើភាពចំពោះអ្នកវិនិយោគទាំងអស់ ។
- នាំមុខជាងបណ្តារប្រទេសមួយចំនួននៅក្នុងតំបន់ ចំពោះការ ការពារអ្នកវិនិយោគ[2] ។
- គ្មានការត្រួតពិនិត្យតម្លៃលើទំនិញ ឬសេវាកម្ម ។
- គ្មានការត្រួតពិនិត្យលើការប្តូររូបិយវត្ថុបរទេសឬគ្មានការដាក់កំហិតលើការប្តូរប្រាក់ ។
- គ្មានការដាក់កំហិតលើការបង្វិលដើមទុនទៅប្រទេសរបស់ អ្នកវិនិយោគវិញ ។
- ជាប្រទេសដំបូងគេក្នុងចំណោមប្រទេសមានការអភិវឌ្ឍន៍តិច (LDC) ដែលបានចូលសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ។
- គ្មានការដាក់កំហិតលើបរិមាណពាណិជ្ជកម្ម បន្ថយរបាំងពន្ធគយ ។ ប្រទេសកម្ពុជាទទួលបានការអនុគ្រោះពន្ធគយ និងកូតាទៅកាន់ទីផ្សារធំៗរបស់ពិភពលោក (ដូចជាសហរដ្ឋអាមេរិក សហភាពអឺរ៉ុប ប្រទេសជប៉ុន និងប្រទេសសមាជិកអាស៊ានជាច្រើន ។
- អាជ្ញាធរខេត្តមានសិទ្ធិអំណាចក្នុងការអនុម័តការវិនិយោគ ក្រោមទឹកប្រាក់ ២ លានដុល្លារអាមេរិកដើម្បីជំរុញការ ចាប់ផ្តើមអភិវឌ្ឍអាជីវកម្មអោយបានឆាប់រហ័ស ។

*"ប្រទេសកម្ពុជាកំពុងបើកចំហទាំងស្រុងចំពោះអាជីវកម្ម ហើយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានឹងព្យាយាមអោយអស់ពីលទ្ធភាព ដើម្បីធានាបាននូវបរិយាកាសអនុគ្រោះ និងភាពជោគជ័យ សម្រាប់រាល់សហគ្រាសទាំងអស់នៅក្នុងប្រទេសកម្ពុជា"។*

- សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

### កម្លាំងពលកម្មតម្លៃទាប និងមានផលិតភាព

ដោយប្រៀបធៀបទៅនឹងអ្នកប្រកួតប្រជែងជាច្រើននៅក្នុងតំបន់ ប្រទេសកម្ពុជាមានអត្រាប្រាក់ឈ្នួលប្រកួតប្រជែង ហើយកម្លាំងពលកម្មមានផលិតភាពខ្ពស់ ធ្វើអោយប្រទេសកម្ពុជាក្លាយជាទិសដៅដ៏ទាក់ទាញសម្រាប់ឧស្សាហកម្ម ដែលប្រើប្រាស់កម្លាំងពលកម្មច្រើន ។

កាលពីប៉ុន្មានឆ្នាំថ្មីៗកន្លងទៅនេះ កម្លាំងពលកម្មរបស់ប្រទេសកម្ពុជាបានកើនឡើងជាង ៥០%ច្រើនជាងទ្វេដងនៃអត្រានៅក្នុងប្រទេសផ្សេងៗរបស់អាស៊ាន[3] ។ ដោយសារតែមានប្រជាជនវ័យក្មេងច្រើន (ប្រជាជនពាក់កណ្តាលមានអាយុក្រោម ២០ ឆ្នាំ) កម្លាំងពលកម្មនេះនឹងបន្តកើនឡើង ។

### តម្លៃពលកម្មនៅក្នុងឧស្សាហកម្មកាត់ដេរ (ឆ្នាំ២០០៨)

| ប្រទេស | ដុល្លារអាមេរិកក្នុងមួយម៉ោង រួមទាំងបន្ទុកសង្គម |
|---|---|
| ថៃ | 1.29-1.36 |
| ម៉ាឡេស៊ី | 1.18 |
| ចិនដីគោក | 1.08 |
| ចិនតំបន់ឆ្នេរ | 0.86-0.94 |
| ចិនជនបទ | 0.55-0.8 |
| ឥណ្ឌូនេស៊ី | 0.44 |
| វៀតណាម | 0.38 |
| កម្ពុជា | 0.33 |

ប្រភព : Jassin-O'Rourke Group ការវិភាគតម្លៃពលកម្មផលិតសម្លៀកបំពាក់ជាសាកល ឆ្នាំ២០០៨

*"ដូចជាប្រទេសចិន និងឥណ្ឌា នៅក្នុងសម័យកាលមុនៗដែរ ប្រទេសកម្ពុជាត្រូវបានកំណត់ថាជាកន្លែងដែលរំពឹងទុកនៅពេលអនាគតសម្រាប់ការវិនិយោគខាងការផលិត ជាពិសេស ដោយសារតែពលកម្មតម្លៃទាបនិងបុព្វលាភហានិភ័យរបស់ប្រទេសទាប...*

*ប្រទេសកម្ពុជាក៏ទទួលបានអត្ថប្រយោជន៍ ពីភាពស្ថិតនៅជិតល្មមទៅនឹងឆ្នេរខាងលិចនៃសហរដ្ឋអាមេរិក" ។*

- PriceWaterhouseCoopers.

### ទីតាំងជាយុទ្ធសាស្ត្រក្នុងតំបន់

ប្រទេសកម្ពុជាមានទីតាំងយ៉ាងល្អឥតខ្ចោះ នៅចំចំណុចកណ្តាលតំបន់ដែលមានថាមភាពបំផុតនៅក្នុងពិភពលោក ។ ដោយស្ថិតនៅជាប់ប្រទេសថៃ និងវៀតណាម ប្រទេសកម្ពុជាគឺជាផ្នែករបៀងសេដ្ឋកិច្ចភាគខាងត្បូង នៃមហាអនុតំបន់ទន្លេមេគង្គ ដែលលាតសន្ធឹងពីទីក្រុងហូជីមិញដល់ទីក្រុងបាងកក ។

ដោយសារតែ ទីតាំងយុទ្ធសាស្ត្របែបនេះ ប្រទេសកម្ពុជាទទួលបានការគាំទ្រពីអន្តរជាតិគួរអោយកត់សម្គាល់នៅក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនរបស់ខ្លួន ដើម្បីជួយសម្រួលដល់ការធ្វើពាណិជ្ជកម្មនៅក្នុងប្រទេស និងជាមួយប្រទេសជិតខាង ។ ជាលទ្ធផលការធ្វើពាណិជ្ជកម្មជាមួយប្រទេសវៀតណាម និងថៃកំពុងរីកចម្រើនយ៉ាងឆាប់រហ័ស ។

1. *មូលនិធិបេតិកភណ្ឌ សន្ទស្សន៍សេរីភាពសេដ្ឋកិច្ចឆ្នាំ២០០៩* http://www.heritage.org/index/
2. *ធនាគារពិភពលោក ស្តីពីការធ្វើអាជីវកម្មឆ្នាំ២០០៩* http://www.doingbusiness.org/
3. *អង្គការពលកម្មអន្តរជាតិ "ពលកម្ម និងនិន្នាការសង្គមនៅក្នុងអាស៊ាន ឆ្នាំ២០០៧ - សមាហរណកម្មបញ្ហាប្រឈម និងកាលានុវត្តភាព" ឆ្នាំ២០០៧*






*"អ្នកមានទីក្រុងធំៗបំផុតពីរនៅអាស៊ីអមសងខាង។ អ្នកមានប្រជាជន ១៥ លាននាក់នៅទីក្រុងបាងកក និង ៨ លាននាក់នៅទីក្រុងហូជីមិញ ហើយអ្វីៗនឹងកើតមានកាន់តែច្រើនឡើងៗ ចន្លោះទីក្រុងទាំងពីរនេះ។*

- Edward Hopkins, CB Richard Ellis Group Inc.




# ហេតុផលប្រាំបីយ៉ាងក្នុងការធ្វើវិនិយោគក្នុងខេត្តពោធិ៍សាត់

## ១. ទីតាំងមូលដ្ឋានល្អសមស្របសម្រាប់ពាណិជ្ជកម្មក្នុងស្រុក និងនាំចេញ

ពោធិ៍សាត់ ដែលជាខេត្តធំទីបួននៅប្រទេសកម្ពុជា មានទីតាំងល្អ និងផ្តល់នូវមូលដ្ឋានល្អសមស្របសម្រាប់ប្រតិបត្តិការពាណិជ្ជកម្ម: វាស្ថិតនៅចន្លោះទីក្រុងធំជាងគេទាំងពីរនៅប្រទេសកម្ពុជា (ភ្នំពេញ និងបាត់ដំបង) និងមានព្រំប្រទល់ជាប់ជាមួយបឹងទន្លេសាប និងប្រទេសថៃ។

ខេត្តមានហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនល្អប្រសើរ និងជាមជ្ឈមណ្ឌលដឹកជញ្ជូន និងពាណិជ្ជកម្មមួយ ដែលស្ថិតនៅលើផ្លូវថ្នល់ភ្ជាប់ភ្នំពេញទៅប្រទេសថៃ និងឆ្ពោះទៅប្រទេសវៀតណាម។

### បណ្តាញផ្លូវថ្នល់

ដោយធ្វើដំណើរតាមរថយន្ត ក្រុងពោធិ៍សាត់ត្រូវការពេល តែ ៣ ម៉ោងប៉ុណ្ណោះទៅកាន់ភ្នំពេញ និងពីប្រទេសថៃ។ ផ្លូវជាតិលេខ ៥ ភ្ជាប់ភ្នំពេញទៅប្រទេសថៃ ដោយឆ្លងកាត់តាមខេត្តពោធិ៍សាត់។ ផ្លូវនេះជាផ្នែកមួយនៃផ្លូវអាស៊ាន លេខ ១ ដែលភ្ជាប់ក្រុងបាងកកទៅក្រុងហូជីម៉ិញ និងជាគម្រោងហេដ្ឋារចនាសម្ព័ន្ធសំខាន់មួយទាំងក្នុងស្រុក និង ក្នុងតំបន់ ដែលជាបង្អែក ដើម្បីបង្កើនពាណិជ្ជកម្មឆ្លងដែន។

ល័ក្ខខ័ណ្ឌផ្លូវថ្នល់នៅក្នុងខេត្តទាំងមូល ត្រូវបានកែលំអបានច្រើន នៅក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅនេះ។ ក្រោយពេលផ្លូវជាតិលេខ ៥ ត្រូវបានជួសជុលប្រវែង ១៣០ គម ធនាគារអភិវឌ្ឍន៍អាស៊ីបានរាយការណ៍ថា មានការកើនឡើងនៃចរាចរណ៍ចំនួន ២៤៧% និងកាត់បន្ថយថ្លៃចំណាយ ប្រតិបត្តិការយានយន្តជាមធ្យមចំនួន ៣៥%។

លើសពីនេះទៅទៀត ផ្លូវជាតិលេខ ៥៧ ដែលភ្ជាប់ព្រំប្រទល់ថៃ ជាមួយនឹងខេត្តប៉ៃលិន ហើយផ្លូវជាតិលេខ ៥៥ ដែលភ្ជាប់ទៅ ព្រំដែនថៃខេត្តត្រាត បច្ចុប្បន្នក៏កំពុងតែជួសជុលកែលម្អផងដែរ។

**កម្ពុជា_ខេត្តពោធិ៍សាត់ រយៈពេលធ្វើដំណើរតាមរថយន្តទៅកាន់ទីរួមខេត្តឬក្រុងនានា**




សញ្ញាព្រួញតំណាងឱ្យរយៈពេលនៃការធ្វើដំណើរដោយរថយន្តគិតជាម៉ោងរយៈពេលធ្វើដំណើរទៅកាន់ទីក្រុងបាងកក និង ហូជីមិញ មិនរាប់បញ្ចូលរយៈពេលឆ្លងកាត់ព្រំដែនទេ

*"ផ្លូវភ្ជាប់ភ្នំពេញទៅបាត់ដំបង មានសភាពល្អប្រសើរ និងបានដាក់ខេត្តពោធិ៍សាត់មកលើផែនទីវិញ។"*

- Lonely Planet, ប្រទេសកម្ពុជា ឆ្នាំ២០០៧

### ផ្លូវដែក

រាជរដ្ឋាភិបាលកម្ពុជាបានចាប់ផ្តើមការងារ ដើម្បីកែលំអផ្លូវដែកអោយមានភាពល្អប្រសើរពីភ្នំពេញទៅប៉ោយប៉ែត ជាប់ព្រំដែនថៃ ដោយឆ្លងកាត់តាមខេត្តពោធិ៍សាត់។ ប្រការនេះនឹងធ្វើអោយការដឹកជញ្ជូន និងពាណិជ្ជកម្មកាន់តែប្រសើរឡើងបន្ថែមទៀតរវាងខេត្តពោធិ៍សាត់ និងប្រទេសថៃ ក៏ដូចជាភ្នំពេញផងដែរ។

### ផ្លូវទឹក

ក្រុងពោធិ៍សាត់ស្ថិតនៅតាមស្ទឹងពោធិ៍សាត់ ដែលហូរពីជួរភ្នំក្រវាញចាក់ចូលទៅបឹងទន្លេសាប។ ស្ទឹងនេះមានលក្ខណៈល្អសមស្របសម្រាប់ការធ្វើដំណើរ និងការដឹកជញ្ជូន ហើយវាជាចំណុចសំគាល់នៃអត្តសញ្ញាណរបស់ក្រុង និងត្រូវបានប្រើប្រាស់សម្រាប់ការដឹកជញ្ជូនផងដែរ។ តំបន់ ១០% ក្នុងខេត្ត គឺបឹងទន្លេសាប។ យើងអាចធ្វើដំណើរតាមទូកទៅខេត្តសៀមរាប កំពង់ធំ និងទីក្រុងភ្នំពេញបាន។

## ២. កម្លាំងពលកម្មវ័យក្មេង មានការអប់រំ និងមានតម្លៃទាប

កម្លាំងពលកម្មរបស់យើងមានវ័យក្មេង ស្វាហាប់ និងមានការអប់រំ។ ជាមួយនឹងប្រជាជនប្រហែលពាក់កណ្តាលនៃប្រជាជនសរុប ចំនួន ៤២៧.០០០នាក់ មានអាយុក្រោម ១៨ ឆ្នាំ កម្លាំងពលកម្មនឹងបន្តកើនឡើងថែមទៀត។

យើងមានសិស្សចំនួន ១០០.០០០ នាក់ដែលរៀននៅសាលាបឋមសិក្សា និងមធ្យមសិក្សារបស់យើង។ មជ្ឈមណ្ឌលបណ្តុះបណ្តាលធំៗបី និងសាកលវិទ្យាល័យពីរធ្វើអោយកម្លាំងពលកម្មរបស់ខេត្តពោធិ៍សាត់ ទទួលបានការបណ្តុះបណ្តាលល្អជាពិសេស។ ជំនាញវិជ្ជាជីវៈនៅក្នុងវិស័យដូចជា ជាងឈើ ជាងម៉ាស៊ីន ជំនាញកុំព្យូទ័រ តម្បាញ ត្រូវបានបណ្តុះបណ្តាល។

# ហេតុផលប្រាំបីយ៉ាងក្នុងការធ្វើវិនិយោគក្នុងខេត្តពោធិ៍សាត់





ការចំណាយលើការអប់រំបឋមសិក្សា ដែលជាចំណែកនៃ GDP មានការកើនឡើងគួរអោយកត់សម្គាល់នៅប្រទេសកម្ពុជានៅក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅថ្មីៗនេះ ហើយបច្ចុប្បន្នអាចប្រៀបធៀបទៅនឹងប្រទេសថៃបាន។ ខេត្តពោធិ៍សាត់មិនមានការលើកលែងចំពោះប្រការនេះទេ។ សាលាខេត្តគ្រោងបន្តបង្កើនការចំណាយលើការអប់រំ។

កម្លាំងពលកម្មគ្មានជំនាញនៅខេត្តពោធិ៍សាត់ មានតម្លៃចាប់ពី ៥០ ដុល្លារក្នុងមួយខែ (បូកនឹងថ្លៃអាហារ និងការស្នាក់នៅនៅក្នុងករណីខ្លះ)។ កម្លាំងពលកម្មដែលមានជំនាញ និងបទពិសោធន៍មានតម្លៃចាប់ពី ១០០ ដុល្លារក្នុងមួយខែ គឺថោកជាងខ្លាំងបើប្រៀបធៀបជាមួយខេត្តជិតខាងរបស់យើងមួយចំនួន។

យើងមានមោទនភាព ដែលមានធនធានមនុស្សនាំមុខគេ ដើម្បីគាំទ្រដល់ពាណិជ្ជកម្មរបស់យើង និងជឿជាក់ថាកម្លាំងពលកម្មដ៏ខ្លាំងក្លា និងមានតម្លៃទាបរបស់យើងក្លាយជាអត្ថប្រយោជន៍មួយ ដែលធ្វើអោយភាពប្រកួតប្រជែងខ្លាំងជាងគេ។ ដូច្នេះអនុញ្ញាតអោយប្រជាជនរបស់យើងជួយធ្វើអោយសហគ្រាសរបស់អ្នកមានការរីកចម្រើន។

## ៣. រដ្ឋអំណាចមូលដ្ឋានផ្តល់ការគាំទ្រ

ថ្មីៗនេះ ខេត្តពោធិ៍សាត់ត្រូវបានគេអោយចំណាត់ថ្នាក់ថា ជាខេត្តមួយដែលមានពន្ធដា និងបន្ទុករដ្ឋបាលទាបក្នុងចំណោមខេត្តនៅក្នុងប្រទេស។ ជាងនេះទៅទៀតខេត្តពោធិ៍សាត់របស់យើង ក៏ត្រូវបានគេផ្តល់ចំណាត់ថ្នាក់ល្អផងដែរចំពោះ ថ្លៃដើមផលិតនិងកម្មសិទ្ធទ្រព្យសម្បត្តិ។ យើងមានបំណងផ្តល់ភាពងាយស្រួលដល់លោកអ្នកក្នុងការដំណើរការអាជីវកម្មរបស់លោកអ្នកនៅខេត្តពោធិ៍សាត់។

ឋានៈរបស់យើងត្រូវបានអោយចំណាត់ថ្នាក់តាមរយៈតារាងពិន្ទុបរិយាកាសអាជីវកម្មខេត្តនៃមូលនិធិ IFC-Asia Foundation ឆ្នាំ២០០៩[4]។ តារាងពិន្ទុវាស់វែងពីអភិបាលកិច្ចសេដ្ឋកិច្ច និងគោលនយោបាយចាត់ចែង ដោយសារវាពាក់ព័ន្ធទៅនឹង ការគាំទ្រដល់បរិយាកាសសកម្ម និងរស់រវើក។

យើងនឹងបន្តធ្វើការដើម្បីកែលំអបរិកាស របស់យើងអោយមានភាពល្អប្រសើរ ដើម្បីលើកទឹកចិត្តអោយមានការវិនិយោគ និងអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងខេត្តរបស់យើង។

## ៤. ការផ្គត់ផ្គង់អគ្គិសនីដែលអាចទុកចិត្តបាន

ខេត្តពោធិ៍សាត់ មានការផ្គត់ផ្គង់អគ្គិសនីដែលអាចទុកចិត្ត បានហើយការផ្គត់ផ្គង់រំពឹងថានឹងកើនឡើងនៅក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខទៀត។ យោងតាមក្រុមហ៊ុននៅតាមមូលដ្ឋានការដាច់ចរន្តអគ្គិសនីកម្រនឹងកើតមានណាស់។

ខេត្តពោធិ៍សាត់មានសក្តានុពលវារីអគ្គិសនីដ៏សំខាន់។ អ្នកវិនិយោគបរទេសជាច្រើនកំពុងធ្វើការស្រាវជ្រាវនៅតាមទីតាំងជាច្រើននៅក្នុងខេត្ត ដែលមានសក្តានុពលវារីអគ្គិសនីខ្លាំង។ ជាពិសេស តំបន់មួយនៅស្ទឹងមេទឹក អាចនឹងមានកម្លាំង ២១០ មេហ្គាវ៉ាត់។ រោងចក្រដែលមានកម្លាំង ១៧០ មេហ្គាវ៉ាត់មួយកំពុងតែសាងសង់នៅស្ទឹងអាតៃ។ ចាប់ពីឆ្នាំ២០១០តទៅ រោងចក្រថ្មីដែលមានកម្លាំង ២១០ មេហ្គាវ៉ាត់ នឹងអាចដំណើរការនៅក្នុងខេត្តពោធិ៍សាត់បាន។

អគ្គិសនីនៅក្នុងក្រុងពោធិ៍សាត់ បច្ចុប្បន្ន មានតម្លៃ ១.៣០០ រៀលក្នុងមួយគីឡូវ៉ាត់ម៉ោង (ប្រហែល ០.៣២ ដុល្លារក្នុងមួយគីឡូវ៉ាត់ម៉ោង)។

4. *តារាងពិន្ទុបរិយាកាសអាជីវកម្មខេត្តនៅកម្ពុជា IFC-TAF ២០០៩ បានធ្វើអង្កេតលើក្រុមហ៊ុនចំនួន ១.២៣៤ ពីគ្រប់ខេត្តទាំងអស់នៅប្រទេសកម្ពុជា។*

## ៥. អចលនវត្ថុមានតម្លៃខ្ពស់

ពោធិ៍សាត់ជាខេត្តធំជាងគេទីបួននៃប្រទេសកម្ពុជា។ ទោះបីភាគច្រើនជាតំបន់ភ្នំ ខេត្តមានដីដែលមានតម្លៃសមរម្យ ជាពិសេសសម្រាប់កសិកម្ម។

ដីនៅខេត្តពោធិ៍សាត់ ជាដីមានជីជាតិជាងគេនៅប្រទេសកម្ពុជា។ ជាពិសេស ជីជាតិមានកម្រិតខ្ពស់នៅក្នុងតំបន់ជុំវិញក្រុងពោធិ៍សាត់ និងជិតបឹងទន្លេសាប និងនៅតាមបណ្តោយស្ទឹងពោធិ៍សាត់។

ដីមានតម្លៃថោក គឺ ៣០០ ដុល្លារក្នុងមួយ ហិកតារ ។

មានសម្បទានដីសម្រាប់អ្នកវិនិយោគទុន។ ដីសម្បទានមួយចំនួនបានធ្វើការដាំដុះរួចហើយដូចជា ដំឡូងមី និងកៅស៊ូ។

## ៦. វិស័យសេវាកម្មហិរញ្ញវត្ថុមានការរីកចម្រើន

សាខាធនាគារបីមានទីស្នាក់ការនៅខេត្តពោធិ៍សាត់ រួមជាមួយនិងការិយាល័យនៅតាមស្រុក និងប៉ុស្តិ៍សេវាកម្មមួយចំនួនទៀត។ ក្រៅពីភ្នំពេញ ខេត្តពោធិ៍សាត់មានសាខាច្រើនជាងគេក្នុងបរិមាណប្រជាជន ១០០.០០០ នាក់ (០,៧៦) គិតជាមធ្យមខេត្ត។

លើសពីនេះទៀត ស្ថាប័នមីក្រូហិរញ្ញវត្ថុ មានភាពសកម្មយ៉ាងខ្លាំងនៅក្នុងខេត្តពោធិ៍សាត់។ យើងមានស្ថាប័នមីក្រូហិរញ្ញវត្ថុផ្តល់កម្ចី ៤% នៃស្ថាប័នមីក្រូហិរញ្ញវត្ថុទាំងអស់នៅប្រទេសកម្ពុជា ទោះបីជាយើងមានប្រជាជនតែ ៣% នៃប្រជាជនសរុបប៉ុណ្ណោះ។ ប្រជាជនពេញវ័យនៅខេត្តពោធិ៍សាត់ប្រហែល ១៧% មានកម្ចីពីស្ថាប័នមីក្រូហិរញ្ញវត្ថុ និងជិត ១០% មានគណនីតម្កល់។

## ៧. ទេសចរណ៍

ខេត្តពោធិ៍សាត់សម្បូរតំបន់ទាក់ទាញទេសចរណ៍វប្បធម៌ និងធម្មជាតិ ព្រមទាំងមានសត្វព្រៃយ៉ាងច្រើន សម្រាប់ទាក់ទាញភ្ញៀវទេសចរ ក្នុងស្រុក និងអន្តរជាតិ ។

ខេត្តទទួលភ្ញៀវទេសចរប្រហែល ៣០០.០០០ នាក់ក្នុងមួយឆ្នាំ ភាគច្រើនមកពីកន្លែងផ្សេងទៀតនៃប្រទេសកម្ពុជា។ បច្ចុប្បន្ននេះ មានភ្ញៀវទេសចរបរទេស ប្រហែល ១.០០០ នាក់មកទស្សនាខេត្តពោធិ៍សាត់ ហើយមន្ត្រីនៅតាមមូលដ្ឋានរៀបចំផែនការដើម្បីធ្វើការបង្កើនភ្ញៀវឱ្យកាន់តែច្រើនថែមទៀត។

ភូមិអណ្តែតទឹកនៅកំពង់លួង ជាតំបន់ទេសចរណ៍ដ៏សំខាន់ សម្រាប់ជនបរទេស និងប្រជាជនកម្ពុជា។ ប្រជាជនក្នុងភូមិនោះរស់នៅជាអចិន្ត្រៃយ៍លើបឹងទន្លេសាប ដោយមានទាំងសាលារៀនអណ្តែតទឹក ភោជនីយដ្ឋាន គ្លីនិកព្យាបាល និងអ្វីៗទាំងអស់មានដូច នៅក្នុងក្រុងដែរ។ មានសត្វស្លាបជាច្រើន សម្រាប់ ទស្សនានៅលើបឹងផងដែរ។ កំពង់លួងមានចម្ងាយ ៣៩ គីឡូម៉ែត្រ ទៅ ៤៤ គីឡូម៉ែត្រ (អាស្រ័យលើកម្រិតទឹកបឹង) នៅខាងកើតក្រុងពោធិ៍សាត់។

ឧកញ៉ាឃ្លាំងមឿងជាតំបន់ប្រវត្តិសាស្ត្រដ៏សំខាន់ ដែលមានទីតាំងស្ថិតនៅក្នុងឃុំស្នាមព្រះ ស្រុកបាកាន ដោយបើកបរចេញពីទីរួមខេត្តរយៈពេលតែបន្តិច។ តំបន់នេះជាកន្លែងសក្ការបូជាដែលទាក់ទាញប្រជាជនកម្ពុជាក្នុងខេត្តផ្ទាល់ និងមកពីខេត្តផ្សេងៗ ដើម្បីបន់ស្រន់ និងគោរពបូជា។

ខេត្តមានទីជម្រកដែនបម្រុងសត្វព្រៃមួយចំនួន រួមមាន ល្អាងត្រាច ក្នុងឃុំស្វាយស ស្រុកក្រគរ។ មានរមណីយដ្ឋានមួយកន្លែងដែលបំរើដល់ភ្ញៀវទេសចរ ទេសភាពស្រស់ស្អាត។

ភ្ញៀវទេសចរក៏ទស្សនាព្រៃខៀវស្រងាត់នៅជួរភ្នំក្រវាញផងដែរ។ កន្លែងពេញនិយមមួយទៀត គឺទឹកធ្លាក់ជាអចិន្ត្រៃយ៍នៅជ្រោះច្រកល្បៀក ចម្ងាយ ៣០ គីឡូម៉ែត្រពីក្រុង។





ដោយទទួលស្គាល់ពីសារសំខាន់វប្បធម៌ និងទេសចរណ៍ នៃតំបន់ទាំងនេះ មន្ទីរទេសចរណ៍ខេត្តធ្វើការសហការជិតស្និទ្ធជាមួយក្រសួងបរិស្ថានដើម្បីថែរក្សាអភិរក្សសម្បត្តិជាតិទាំងនេះ។

### ៤. ធនធានធម្មជាតិដែលមិនទាន់ធ្វើអាជីវកម្ម

ពេលដែលកំពុងផ្តោតការយកចិត្តទុកដាក់ខ្ពស់ លើការធានានូវការប្រើប្រាស់ធនធានធម្មជាតិរបស់ប្រទេសប្រកបដោយនិរន្តរភាព ខេត្តពោធិ៍សាត់ក៏ផ្តល់នូវសក្តានុពលរ៉ែយ៉ាងច្រើនផងដែរ។ រ៉ែមានតម្លៃមួយចំនួន មាននៅក្នុងតំបន់ រួមមាន រ៉ែដែក សំណ ថ្មកែវ និងផ្លូស្វាត។

# វិស័យសំខាន់ៗរបស់ខេត្ត

## កសិកម្ម

ដូចដែលបានរៀបរាប់ខាងលើ ខេត្តពោធិ៍សាត់មានវិស័យកសិកម្មដ៏រឹងមាំ ដោយផ្អែកលើដី និងការផ្គត់ផ្គង់ទឹកដ៏ល្អរបស់ខេត្ត។

ខេត្តមានដំណាំស្រូវ ៤% នៃដំណាំស្រូវសរុបនៅប្រទេសកម្ពុជា។ រដូវវស្សាផ្តល់ទិន្នផលជាមធ្យមជាង ២,៥ តោនក្នុងមួយហិកតារ។ មិនទាន់មានកសិដ្ឋានណា ដែលសម្រេចបានទិន្នផលខ្ពស់ជាងនេះនៅឡើយទេ។

នៅក្នុងរដូវប្រាំង ទំនប់ទឹកធំពីរស្រោចស្រពដីទំហំជាង ៧.០០០ ហិកតារ បន្ថែមលើប្រព័ន្ធស្រោចស្រពតូចៗ ផ្សេងទៀតចំនួន ១៧។

ខេត្តក៏ផលិតស្ករត្នោត ដំឡូងជ្វា ល្ង បន្លែចំរុះ សណ្តែក ពោត និងដំឡូងមីជាច្រើនផងដែរ។ ដោយសារវាមានទីតាំងជិតប្រទេសថៃ ដំណាំដំឡូងមីនៅក្នុងខេត្តពោធិ៍សាត់ត្រូវបាននាំចេញទៅប្រទេសថៃ ដែលធ្វើអោយមានសក្តានុពលសម្រាប់ ដំណាំទាំងអស់ក្នុងការទទួលយកគំរូនេះ។

លើសពីនេះទៀត ខេត្តពោធិ៍សាត់មានភាពល្បីល្បាញខាងផ្លែក្រូចពោធិ៍សាត់ ដែលមានរសជាតិផ្អែម។

ការនេសាទត្រីមានសារៈសំខាន់ណាស់សម្រាប់ខេត្ត ជាពិសេស នៅលើបឹងទន្លេសាប។ បសុសត្វក៏មានសារៈសំខាន់សម្រាប់ខេត្តផងដែរ។ ជាពិសេស ខេត្តពោធិ៍សាត់មានកសិដ្ឋានចិញ្ចឹមសត្វមួយចំនួនដូចជា មាន់ ទា គោ ក្របី និង ជ្រូក។

ទិន្នផលកសិកម្មរបស់ខេត្តរំពឹងនឹងមានការកើនឡើងទៀត ក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខនេះ ដែលកសាងនូវមូលដ្ឋានរឹងមាំដែលមានក្នុងពេលបច្ចុប្បន្ន ដោយសារ គុណភាពដី និងការបើកទីផ្សារក្នុង និងក្រៅប្រទេស។ ក្រុមហ៊ុនថ្មីមួយចំនួន បានចុះបញ្ជីជាមួយអាជ្ញាធរមូលដ្ឋាន ដោយមាន គម្រោងដាំដំឡូងមី និងកៅស៊ូ ក្នុងចំណោមដំណាំផ្សេងទៀត។ ក្រុមហ៊ុនទាំងនេះ នីមួយៗវិនិយោគពី ១ លានទៅ ២ លានដុល្លារនៅលើដីពី ៨០០ ទៅ ១០០០ ហិកតារ ក្រុមមួយទៀតមានគម្រោងសាងសង់រោងម៉ាស៊ីនកិនស្រូវធំថ្មីចំនួន ៤ កន្លែងនៅក្នុងខេត្ត។

## ឧស្សាហកម្ម និងសេវាកម្ម

ខេត្តពោធិ៍សាត់មានឡឥដ្ឋជាច្រើន ក្រុមហ៊ុនផ្គត់ផ្គង់គ្រឿងម៉ាស៊ីនកសិកម្ម និងសិប្បករផលិតវត្ថុសិល្បៈ។ ជាពិសេស យើងមានឈ្មោះល្បីខាងចម្លាក់អំពីថ្មកែវ។

យើងក៏មានរោងចក្រទឹកកកចំនួនបីកន្លែង ក្រុមហ៊ុនទឹកស្អាតបីកន្លែង និងក្រុមហ៊ុនផលិតភេសជ្ជៈគ្មានជាតិសុរាមួយផងដែរ។

ជាសរុប យើងមានសហគ្រាសឯកជនជាង ១.០០០ ដែលកំពុងដំណើរការនៅក្នុងខេត្ត រួមមាន:

| សកម្មភាព | ចំនួនសហគ្រាស |
|---|---|
| ភោជនីយដ្ឋាន និងអាហារដ្ឋាន | 329 |
| ហាងជួសជុល | 128 |
| សេវាវិជ្ជាជីវៈ | 19 |
| សេវាផ្សេងៗ | 71 |
| សិប្បកម្មផលិត សិប្បកម្មឧបភោគបរិភោគផ្សេងៗ | 23 |
| សម្ភារៈសេរ៉ាមិច | 18 |
| រោងចក្រផលិតឥដ្ឋ | 124 |
| សិប្បកម្មផលិត គ្រឿងសង្ហារិម | 2 |
| សិប្បកម្ម | 24 |
| សិប្បកម្មផ្សេងៗ | 17 |
| សម្ភារៈសំណង់ផ្សេងៗ | 7 |
| ហាងលក់ដុំ | 7 |
| ហាងលក់រាយគ្រឿងទេស | 113 |
| ហាងលក់រាយផ្សេងៗ | 273 |
| សាកវប្បកម្ម/ដំណាំផ្ទះកញ្ចក់ | 9 |

ប្រភព: មូលនិធិអាស៊ី និង IFC ការចុះបញ្ជីគ្រឹះស្ថានអាជីវកម្ម នៅទីរួមខេត្ត និងតំបន់ទីក្រុងដែលបានជ្រើស នៅប្រទេសកម្ពុជា ខែមីនា ឆ្នាំ២០០៩។

# ឱកាសពាណិជ្ជកម្ម

ខេត្តរបស់យើងមានកត្តាសំខាន់ៗទាំងអស់ សម្រាប់ការពង្រីកពាណិជ្ជកម្ម និងផ្តល់ផលចំណេញ យ៉ាងឆាប់រហ័សដោយសារមានទីតាំងល្អសមស្របសម្រាប់ ជំនួញពាណិជ្ជកម្មធនធានធម្មជាតិសម្បូរបែប និងកម្លាំងពលកម្មច្រើនតែមានតម្លៃទាប។ ដោយសារមានលក្ខណៈពិសេសទាំងនេះ មន្ត្រីក្នុងស្រុក និងសភាពាណិជ្ជកម្មខេត្តពោធិ៍សាត់ មានការរំភើបជាមួយនឹងសក្តានុពលរបស់ខេត្ត។ ពេលចាប់ផ្តើម ទាញយកប្រយោជន៍ពីឱកាសដែលមានស្រាប់នៅក្នុងខេត្ត យើងឃើញមានឱកាសជាច្រើនសម្រាប់ក្រុមហ៊ុន ក្នុងការទាញយកប្រយោជន៍ពីចំណុចខ្លាំងប្រកបដោយភាពប្រកួតប្រជែងរបស់យើង តាមរយៈការវិនិយោគបន្ថែមលើវិស័យ:





**កសិកម្ម និងកសិ-ពាណិជ្ជកម្ម** ជាពិសេស ដូចជាការកែច្នៃម្ហូបអាហារ ដំឡូងមី និងកៅស៊ូ។ យើងមានលទ្ធភាពច្រើន ដើម្បីបន្ថែមតម្លៃ លើផលិតផល កសិកម្មជាច្រើន និងផលិតផលផ្សេងៗរបស់យើង។ ដំណាំងល្ហុងខ្វងបានធ្វើការដាំនៅក្នុងខេត្ត ដូច្នេះមានសក្តានុពលសម្រាប់ការកែច្នៃដំណាំនេះ អោយក្លាយជាជីវឥន្ធនៈ។ ក្នុងនាមជាខេត្តផលិតស្រូវមួយធំនេះធ្វើឱ្យមានលទ្ធភាពលើការវិនិយោគ រោងម៉ាស៊ីនកិនស្រូវ និងសមត្ថភាពស្តុកស្រូវ។

**ឧស្សាហកម្មធុនស្រាល** រួមមាន កាត់ដេរ។ យើងមានកម្លាំងពលកម្មដែលមានតម្លៃទាប ហេដ្ឋារចនាសម្ព័ន្ធល្អ និងបរិយាកាសគាំទ្រ ។យើងក៏មានលទ្ធភាពសម្រាប់ការវិនិយោគបន្ថែមនៅក្នុងការផលិតឥដ្ឋ ដែលអ្នកផលិតឥដ្ឋនៅមូលដ្ឋានមិនអាចបំពេញតាមតម្រូវការនៅទូទាំងប្រទេសគ្រប់គ្រាន់។

**ទេសចរណ៍:** យើងឃើញមានសក្តានុពលខ្លាំងក្លា ដើម្បី ធ្វើអោយហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មទេសចរណ៍របស់ យើងមានភាពរីកចម្រើន ជាពិសេស សម្រាប់ទីផ្សារទេសចរណ៍ក្នុងស្រុកដែលរីកចម្រើន ។ ជាឧទាហរណ៍ វិនិយោគ ទៅលើទូកថ្មីៗ សម្រាប់ការធ្វើដំណើររបស់ភ្ញៀវទេសចរ ទៅភូមិអណ្តែតទឹក។

**រ៉ែ:** វិនិយោគិនបរទេសជាច្រើនកំពុងធ្វើការស្រាវជ្រាវ អំពីសក្តានុពលនៃរ៉ែអាលុយមីញ៉ូម និងបុកស៊ីត នៅក្នុងចំណោមរ៉ែផ្សេងៗ។

## ការអភិវឌ្ឍន៍ដែលកំពុងដំណើរការ

ទោះបីជាយើងមានមោទនភាពចំពោះសមិទ្ធផលរបស់យើងក៏ដោយ យើងនៅតែបន្តពង្រឹង និងកែលំអការទាក់ទាញ វិនិយោគទុនរបស់យើងអោយកាន់តែប្រសើរឡើង។ យើងនឹងបន្តធ្វើការយ៉ាងសកម្មនៅក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធ អាជីវកម្មរបស់យើង និងទាក់ទាញសហគ្រាសពាណិជ្ជកម្មនាំមុខគេមកកាន់ខេត្តរបស់យើង។ ការអភិវឌ្ឍន៍ចម្បងៗមួយចំនួន ដែលកំពុងដំណើរការមាន :

- យុទ្ធសាស្ត្រវិនិច្ឆ័យសមាហរណកម្មពាណិជ្ជកម្ម របស់រាជរដ្ឋាភិបាលកម្ពុជា។ ក្រោមកម្មវិធីនេះ ផលិតផលរបស់ខេត្តពោធិ៍សាត់ជាច្រើន ទទួលបានការគាំទ្របន្ថែម។ ផលិតផលដែលត្រូវបានកំណត់ក្រោមយុទ្ធសាស្ត្រនេះ រួមមាន កាត់ដេរស្បែកជើង ឧស្សាហកម្មធុនស្រាល ការដឹកជញ្ជូន និង ទេសចរណ៍។ ជំនួយរួមមានការសម្របសម្រួលពាណិជ្ជកម្ម និងការលើកស្ទួយវិនិយោគ កំណែទម្រង់ច្បាប់ និងការកសាងសមត្ថភាពគ្រប់គ្រង និង ជំនាញមូលដ្ឋាន។
- ដៃគូអភិវឌ្ឍន៍ជាច្រើន កំពុងជួយអភិវឌ្ឍវិស័យឯកជន នៅខេត្តពោធិ៍សាត់ នៅក្នុងឧស្សាហកម្មចម្បងៗ :

| គម្រោង | ដៃគូអភិវឌ្ឍន៍ | វិស័យ |
|---|---|---|
| គម្រោងពង្រឹងសហគ្រាសខ្នាតតូចបំផុត ខ្នាតតូច និងខ្នាតមធ្យមកម្ពុជា (USAID Cambodia MSME) | USAID | ផ្នែកឥដ្ឋក្បឿង វារីវប្បកម្ម ជ្រូក ទឹកស្អាត និងអនាម័យ ផ្លែឈើ ទឹកឃ្មុំ ជ័រទឹក ផ្នែកឧស្សាហកម្មកាត់ដេរ និងទេសចរណ៍ |
| គម្រោងផ្សព្វផ្សាយវិស័យកសិកម្មកម្ពុជាអូស្ត្រាលី ដំណាក់កាលទី ២ | AusAID | កសិកម្ម |
| គម្រោងចិញ្ចឹមបសុសត្វខ្នាតតូច SLPP | EU | បសុសត្វ |
| ការលើកស្ទួយវិស័យឯកជន | GTZ | ស្វាយចន្ទី ស្រូវសរីរាង្គ សូត្រ ICT |
| គម្រោងស្តារធារាសាស្ត្រភាគពាយ័ព្យ | AFD / ADB | កសិកម្ម ការស្រោចស្រព |

# ត្រូវការស្វែងយល់បន្ថែមទៀតទេ ?

សំរាប់ព័ត៌មានបន្ថែមស្តីអំពីឱកាសវិនិយោគនិងការអភិវឌ្ឍន៍
នៅក្នុងខេត្តពោធិ៍សាត់ សូមទាក់ទង:
ខុទ្ទកាល័យសាលាខេត្តពោធិ៍សាត់
ទូរស័ព្ទ: +(855) 052 951 442

សភាពាណិជ្ជកម្មខេត្តពោធិ៍សាត់
ទូរស័ព្ទ: +(855) 052 951 995

**www.investincambodia.com**

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា – គណៈកម្មាធិការវិនិយោគកម្ពុជា
ទូរស័ព្ទ : +(855) 23 981 154
**www.cambodiainvestment.gov.kh**

វិទ្យាស្ថានជាតិ ស្ថិតិ
www.nis.gov.kh

**ក្រសួងផ្សេងៗ:**
ក្រសួងពាណិជ្ជកម្ម
www.moc.gov.kh
ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
www.mef.gov.kh
ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
www.mine.gov.kh
ក្រសួង ការងារនិង បណ្តុះបណ្តាល វិជ្ជាជីវៈ
www.nlv.gov.kh
ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
www.mlmupc.gov.kh
ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
www.mptc.gov.kh
ក្រសួងសាធារណការ និង ដឹកជញ្ជូន
www.mpwt.gov.kh
ក្រសួងទេសចរណ៍
www.mot.gov.kh
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
www.maff.gov.kh

**ផ្សេងៗ:**
សមាគមរោងចក្រកាត់ដេរនៅកម្ពុជា
www.gmac-cambodia.org
វេទិកាវិស័យឯកជន-រដ្ឋាភិបាល
www.cambodia-gpsf.org
សភាពាណិជ្ជកម្មភ្នំពេញ
www.ppcc.org.kh

## ព័ត៌មានសង្ខេបពីខេត្តពោធិ៍សាត់

| | |
|---|---|
| ប្រជាជន: | 426,758 |
| សមាមាត្រការងារផ្នែកកសិកម្ម: | 85% |
| ចំណាត់ថ្នាក់ភាពក្រីក្ររបស់ខេត្ត: | 13/24 |
| ផ្ទៃដី: | 12,692 គម២ |
| ដង់ស៊ីតេប្រជាជន:<br>(% នៃមធ្យមភាគជាតិ) | 33.6 នាក់/គម២<br>45% |
| ចំនួនក្រុង / ស្រុក: | ក្រុង1 និង 5 ស្រុក |
| ចំនួនឃុំ /សង្កាត់: | 42ឃុំ និង 7សង្កាត់ |

## ដីនៅខេត្តពោធិ៍សាត់

| |
|---|
| ប្រភេទ : ដីល្បាប់បឹងនៅក្នុងតំបន់ដែលនៅជិតបឹងទន្លេសាប ដីល្បាប់ពណ៌ត្នោតតាមបណ្តោយស្ទឹងពោធិ៍សាត់ ដីមានទឹកច្រើនពណ៌ប្រផេះជុំវិញក្រុង ដីផេះពណ៌ក្រហម-លឿង និងដីប្រភេទថ្មមានជាតិអាស៊ីត នៅកន្លែងផ្សេងទៀត។ |
| កម្រិតជីជាតិ : ខ្ពស់នៅជុំវិញក្រុងពោធិ៍សាត់ និងនៅក្នុង តំបន់ជាប់បឹងទន្លេសាប កម្រិតជីជាតិមធ្យម នៅតាមបណ្តោយស្ទឹងពោធិ៍សាត់ កម្រិតជីជាតិទាបនៅតំបន់ភ្នំខាងលិច។ |

## អត្រាពន្ធកម្ពុជា

| | | |
|---|---|---|
| ពន្ធលើប្រាក់ចំណេញ | ធម្មតា | 20% |
| | អត្រាលើកទឹកចិត្ត | 0% ឬ 9% |
| | | |
| ពន្ធអប្បបរមា | | 1% នៃផលរបរ |
| ពន្ធកាត់ទុក | | 15% |
| ប្រាក់ចំណូលពីការជួលអចលនវត្ថុ | | 10% |
| ការបង់ប្រាក់ជូនអនិវាសនជន | | 14% |
| | | |
| ពន្ធលើប្រាក់បៀវត្សរ៍ (រៀលក្នុងមួយខែ) | | |
| 0-500,000 | | 0% |
| 500,001-1,250,000 | | 5% |
| 1,250,001-8,500,000 | | 10% |
| 8,500,001-12,500,000 | | 15% |
| 12,500,001 + | | 20% |
| អនិវាសនជន | អត្រាថេរ | 20% |
| ពន្ធលើផលបន្ទាប់បន្សំ | | 20% |
| ពន្ធលើតម្លៃបន្ថែម | | 10% |
| | នាំចេញ | 0% |
| ពន្ធលើការផ្ទេរសិទ្ធិអចលនវត្ថុ | | 4% |

# ស្ថិតិ

| ទិន្នន័យម៉ាក្រូសេដ្ឋកិច្ចកម្ពុជា | 2005 | 2006 | 2007 | 2008 |
|---|---|---|---|---|
| កំណើន GDP (%) | 13.5 | 10.8 | 9.6 | 5.5 |
| កំណើននាំចេញ (%) | 12.6 | 26.9 | 10.7 | 8.8 |
| នាំចេញ (% GDP) | 64.2 | 68.0 | 66.7 | 68.8 |
| វិនិយោគផ្ទាល់ពីបរទេស FDI (លានដុល្លា) | 375 | 475 | 867 | 790 |
| វិនិយោគផ្ទាល់ពីបរទេស FDI (% GDP) | 6.0 | 6.5 | 6.9 | 6.0 |

## ថ្លៃអាជីវកម្ម

| ដី | លក់ (ក្នុងមួយម៉ែត្រការ៉េ) |
|---|---|
| រាជធានីភ្នំពេញ | $350-$2,000 |
| ដីពាណិជ្ជកម្ម | $30-$200 |
| តំបន់ផ្សេងទៀត | $4-$50 |
| ជនបទ | $0.5-$5 |

| ទីតាំងការិយាល័យ | ថ្លៃឈ្នួលក្នុងមួយខែ |
|---|---|
| សំខាន់ | $9-11/មួយម៉ែត្រការ៉េ |
| បន្ទាប់បន្សំ | $6-8/មួយម៉ែត្រការ៉េ |
| ថ្លៃឈ្នួលរោងចក្រ | $1.50-$2.50/មួយម៉ែត្រការ៉េក្នុងមួយខែ |
| ថ្លៃឈ្នួលឃ្លាំង | $1.00-$2.50/មួយម៉ែត្រការ៉េក្នុងមួយខែ |

| ថ្លៃអគ្គិសនីនៅរាជធានីភ្នំពេញ (លើកលែងតំបន់សេដ្ឋកិច្ចពិសេស) | | |
|---|---|---|
| | គីឡូវ៉ាត់ម៉ោងក្នុង ១ ខែ) | តម្លៃ (រៀលក្នុង ១ គីឡូវ៉ាត់ម៉ោង |
| ឧស្សាហកម្ម | <45,000 | 600 |
| | 45,000-130,000 | 550 |
| | >130,000 | 500 |
| | តង់ស្យុងមធ្យម | 480 |
| ពាណិជ្ជកម្ម | <45,000 | 650 |
| | 45,000-130,000 | 600 |
| | >130,000 | 500 |
| | តង់ស្យុងមធ្យម | 480 |
| ការផ្គត់ផ្គង់ហ្គាសដល់ឧស្សាហកម្ម | | $0.32/គ.ក្រ |

| តម្លៃពលកម្ម | ប្រាក់បៀវត្សរ៍ ដុល្លារក្នុងមួយខែ |
|---|---|
| អ្នកចាត់ការជាន់ខ្ពស់ | 1,000-1,500 |
| អ្នកចាត់ការមធ្យម | 500-1,000 |
| អ្នកចាត់ការកម្រិតដំបូង | 240-400 |
| គណនេយ្យករ | 250-400 |
| លេខាធិការ | 120-150 |
| ស្មៀនការិយាល័យ | 100-120 |
| អ្នកបើកបរ | 100-120 |
| អ្នកយាម | 50-80 |
| កម្មករ | 50-80 |
| ប្រាក់បៀវត្សរ៍អប្បបរមាសម្រាប់កម្មកររោងចក្រកាត់ដេរ | 60 |

# ខេត្តពោធិ៍សាត់

## សក្ដានុពលវិនិយោគ









Photographs by Nathan Horton www.nathanhortonphotography.com, and Conservation international

Designed by DESIGNGROUP www.dgcambodia.com